ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# ផែនការយុទ្ធសាស្ត្រ
# បញ្ញាបយេនឌ័រក្នុងវិស័យអប់រំ
# ២០២៥-២០២៩

ខែធ្នូ ២០២៥

# អារម្ភកថា

ក្នុងរយៈពេល ៥ឆ្នាំកន្លងមក ក្រសួងអប់រំ យុវជន និងកីឡាសម្រេចបានសមិទ្ធផលធំៗគួរឱ្យកត់សម្គាល់លើការងារឆ្លើយតបនឹងសមភាពយេនឌ័រ និងការកសាងបរិស្ថានអប់រំ ដូចជា ៖ ការកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំ ការបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ និងការបណ្តុះឥរិយាបថវិជ្ជមានរបស់សង្គមឆ្លើយតបទៅនឹងយេនឌ័រក្នុងវិស័យអប់រំ។

ឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨ សំដៅពង្រឹងសមភាពយេនឌ័រនៅគ្រប់កម្រិត និងគ្រប់វិស័យ និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ ឈរលើមូលដ្ឋាននេះ ក្រសួងបានប្តេជ្ញាចិត្តលើកកម្ពស់សមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត ការបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ និងការកសាងបរិស្ថានអប់រំ និងឥរិយាបថវិជ្ជមានរបស់សង្គម ដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។

ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២៥-២០២៩ ដោយផ្អែកលើវឌ្ឍនភាពសម្រេចបាន និងបញ្ហាប្រឈមនានានៃការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥ និងគ្របដណ្តប់លើគ្រប់អនុវិស័យ ក្នុងការលុបបំបាត់អំពើហិង្សា ការជួញដូរស្ត្រីនិងកុមារ ការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទគ្រប់រូបភាព ការផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ការផ្តល់ភាពអង់អាចដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រង និងដឹកនាំឱ្យកាន់តែល្អប្រសើរឡើង។ ផែនការនេះ បង្ហាញពីទំនាក់ទំនងច្បាស់លាស់រវាងគោលបំណង ក្របខណ្ឌយុទ្ធសាស្ត្រ និងសកម្មភាព ដែលផ្តល់ភាពងាយស្រួលក្នុងការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ រួមជាមួយនឹងយន្តការសម្រាប់ផ្តល់ព័ត៌មានត្រឡប់ និងការពិនិត្យឡើងវិញ។

ក្រសួងអប់រំ យុវជន និងកីឡា សូមកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ដែលបានចូលរួមគាំទ្រ និងរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២៥-២០២៩ ឱ្យសម្រេចបានដោយជោគជ័យ។ ក្រសួងសង្ឃឹមថា អ្នកពាក់ព័ន្ធទាំងអស់ជួយគាំទ្រ និងចូលរួមយ៉ាងសកម្មអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យទទួលបានលទ្ធផលល្អ ដើម្បីអនាគតភ្លឺស្វាង និងរុងរឿង សម្រាប់កុមារ និងយុវជនកម្ពុជាជំនាន់ក្រោយ។da. /

ថ្ងៃ ពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១. | **សេចក្តីផ្តើម** | ១ |
| ២. | **លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២១-២០២៥** | ២ |
| ២.១ | ការបណ្តុះឥរិយាបថសង្គមវិជ្ជមានចំពោះការអប់រំកុមារី និងសមភាពយេនឌ័រក្នុងចំណោមអ្នកពាក់ព័ន្ធវិស័យអប់រំ | ២ |
| ២.២ | ការបង្កើនសមភាពយេនឌ័រនៅក្នុងការអប់រំ និងការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការងារគ្រប់គ្រង | ១៩ |
| ២.៣ | បញ្ហាប្រឈម | ២៤ |
| ៣. | **ចក្ខុវិស័យ** | ២៥ |
| ៤. | **បេសកកម្ម** | ២៥ |
| ៥. | **គោលបំណង** | ២៥ |
| ៦. | **ក្របខណ្ឌយុទ្ធសាស្ត្រ** | ២៥ |
| ៧ | **ផែនការសកម្មភាព** | ៣២ |
| ៧.១ | លទ្ធផលរំពឹងទុក | ៣២ |
| ៧.២ | សូចនាករ និងចំណុចដៅ | ៣២ |
| ៧.៣ | ម៉ាទ្រិកលទ្ធផលសកម្មភាព | ៣៤ |
| ៧.៤ | ម៉ាទ្រិកផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៤-២០២៨ | ៥១ |
| ៨. | **ធនធានហិរញ្ញវត្ថុ** | ៧៦ |
| ៩. | **ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** | ៧៦ |

# អក្សរកាត់

| | |
|---|---|
| ក្រយឧ | ក្រុមការងារយេនឌ័រ |
| កបប | នាយកដ្ឋានកិច្ចការបណ្ដុះបណ្ដាល |
| កវក | នាយកដ្ឋានកិច្ចការវិក្រឹតិការ |
| គកនក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ |
| គប | នាយកដ្ឋានគោលនយោបាយ |
| គយឧ | គណៈកម្មការយេនឌ័រ |
| គឧស | នាយកដ្ឋានគ្រប់គ្រងឧត្ដមសិក្សា |
| តទវ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| ទរសណ | នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងសំណង់ |
| ធម | នាយកដ្ឋានធនធានមនុស្ស |
| នក | នាយកដ្ឋាននីតិកម្ម |
| បឌ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| បពអ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| បស | នាយកដ្ឋានបឋមសិក្សា |
| ផក | នាយកដ្ឋានផែនការ |
| ពវ | នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ |
| មចទ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| រប | នាយកដ្ឋានរដ្ឋបាល |
| សស | នាយកដ្ឋានសុខភាពសិក្សា |
| សអអ | នា.សហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន |
| ហវ | នាយកដ្ឋានហិរញ្ញវត្ថុ |
| អកត | នាយកដ្ឋានអប់រំកុមារតូច |
| អកប | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ  និងបរិយាបន្ន |
| អកយ | នាយកដ្ឋានអភិវឌ្ឍកម្មវិធីយុវជន |
| អកស | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| អគកឡ | អគ្គនាយកដ្ឋានកីឡា |
| អគបផ | អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| អគបវ | អគ្គនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតិការ |
| អគយវ | អគ្គនាយកដ្ឋានយុវជន |
| អគអ | នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ |
| អគអរ | អគ្គនាយកដ្ឋានអប់រំ |
| អគឧស | អគ្គនាយកដ្ឋានឧត្ដមសិក្សា |
| អយក | នាយកដ្ឋានអប់រំយុវជន និងកុមារ |

## ១. សេចក្តីផ្តើម

ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី គឺជាការងារអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥ ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ សំដៅឆ្លើយតបនឹងផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា "លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី" ចំណុចដៅទី១ "កាត់បន្ថយឱ្យបានច្រើននូវគម្លាតយេនឌ័រ ក្នុងការអប់រំកម្រិតមធ្យមសិក្សា" អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ "ការអភិវឌ្ឍមូលធនមនុស្ស" របស់រាជរដ្ឋាភិបាល មុំទី១ ផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាបន្តអនុវត្តគោលនយោបាយ ផែនការ និងកម្មវិធីនានាក្នុងវិស័យអប់រំ ដើម្បីអភិវឌ្ឍមូលធនមនុស្ស រួមទាំងពង្រឹងកិច្ចការពារសិទ្ធិស្ត្រី និងជំរុញសមភាពយេនឌ័រក្នុងវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡាបានលើកទិសដៅដូចខាងក្រោមៈ

- ធានាសម្រេចឱ្យបានសមភាពយេនឌ័រក្នុងការចូលរៀន និងរៀន ប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន នៅគ្រប់សេវាអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ
- ធានាបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ
- ធានាកសាងបរិស្ថានអប់រំ និងឥរិយាបថវិជ្ជមានរបស់សង្គម ដើម្បីឆ្លើយតបទៅនឹងយេនឌ័រ
- សាងសង់សាលារៀនទៅកាន់តែជិតផ្ទះប្រជាជន ដើម្បីបង្កលក្ខណៈឱ្យសិស្សមកពីគ្រួសារក្រីក្របានចូលរៀន ជាពិសេស កុមារី ដើម្បីកាត់បន្ថយចំណាយ និងសុវត្ថិភាពការធ្វើដំណើរ
- សាងសង់ជម្រាលសម្រាប់សិស្សមានពិការភាព
- សាងសង់អន្តេវាសិកដ្ឋានសម្រាប់ការស្នាក់នៅរបស់សិស្ស និស្សិត គរុសិស្សជានារី ដូចជា នៅតាមសាលាគរុកោសល្យ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងសាកលវិទ្យាល័យ
- អនុវត្តកម្មវិធីសាលាកុមារមេត្រី និងកម្មវិធីទីប្រឹក្សាសាលារៀន
- លើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការអប់រំស្ត្រី ដែលការវិនិយោគតាំងពីម្តាយរហូតដល់កូន ព្រមទាំងយកចិត្តទុកដាក់លើផ្នត់គំនិតរបស់សង្គមចំពោះកូនស្រី
- ផ្តល់អាហារូបករណ៍សម្រាប់សិស្សអាទិភាពទូទៅ សិស្សពូកែ អាទិភាពនារី អាទិភាពក្រីក្រ អាទិភាពតំបន់ដាច់ស្រយាល និងសិស្សមានពិការភាព ជាពិសេសសិស្សនារី
- អភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារសិក្សា ការកែលម្អសកម្មភាពបង្រៀន និងរៀនឱ្យមានការទាក់ទាញ ជាពិសេសការលើកកម្ពស់ស្ត្រី កុមារីដោយគ្មានការរើសអើងចំពោះភេទ

– ផ្តល់ការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និង ជំងឺឆ្លងផ្សេងៗទៀត។

## ២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២១-២០២៥

ការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ២០២១-២០២៥ ក្រសួងមានគោលបំណង "ធានាឱ្យកុមារ និងមនុស្សពេញវ័យ ទទួលបានសេវាអប់រំប្រកបដោយសមភាព សមធម៌ បរិយាបន្ន និងសម្រេចបានលទ្ធផលសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព" ដោយមានគោលដៅបីគឺ ១) ធានាសម្រេចឱ្យបានសមភាពយេនឌ័រក្នុងការចូលរៀន និងរៀនប្រកបដោយគុណភាពនៅគ្រប់សេវាអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ ២) ធានាបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ និង ៣) ធានាកសាងបរិស្ថានអប់រំ និងបណ្តុះឥរិយាបថវិជ្ជមានរបស់សង្គមដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។

សមិទ្ធផល និងវឌ្ឍនភាពសំខាន់ៗជាច្រើនក្នុងការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំកន្លងមក មានដូចខាងក្រោម ៖

### ២.១ ការបណ្តុះឥរិយាបថសង្គមវិជ្ជមានចំពោះការអប់រំកុមារី និងសមភាពយេនឌ័រក្នុងចំណោមអ្នកពាក់ព័ន្ធនឹងវិស័យអប់រំ

#### ការអប់រំកុមារតូច

លទ្ធភាពទទួលសេវាអប់រំរបស់កុមារតូចគ្រប់រូបភាព មានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ឆ្នាំសិក្សា២០២៤-២០២៥ កុមារទទួលបានសេវាអប់រំគ្រប់រូបភាព ៤២៥ ៥៣៩នាក់ កើន ២៤ ៥៨០នាក់ ស្រី ២១១ ៩១៣នាក់ កើន ១០ ៦២៣នាក់។ កុមារអាយុ ៣ឆ្នាំមាន ៥៦ ៤៨៧នាក់ កើន ២ ០៦៤នាក់ ស្រី ២៩ ០១២នាក់ កើន ៧១១នាក់។ កុមារអាយុ ៤ឆ្នាំមាន ១៣៨ ៨៦៨នាក់ កើន ១១ ២៨២នាក់ ស្រី ៦៩ ៧១០នាក់ កើន ៤ ៩៥៨នាក់។ កុមារអាយុ ៥ឆ្នាំមាន ២៣០ ១៨៤នាក់ កើន ១១ ២៣៤នាក់ ស្រី ១១៣ ១៩១នាក់ កើន ៥ ៣០៧នាក់។ សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៩ ០៣៦សាលា/កន្លែង កើន ១៤៥សាលា/កន្លែង ដែលមានទីតាំង ១ ១១៩ ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៥២ ឃុំ សង្កាត់។

**រូបភាពទី១៖ អត្រារួមនៃការសិក្សាអប់រំកុមារតូច (៣-៥ឆ្នាំ)**




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រារួមនៃការសិក្សាការអប់រំកុមារតូច (អាយុ៣-៥ឆ្នាំ) មានការកើនពី ៣៤,៨ ភាគរយ ក្នុងឆ្នាំសិក្សា ២០២០-២០២១ ដល់ ៤៣,០ភាគរយ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ កើន ៨,២ ភាគរយ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដោយសារក្រសួងបានប្រកាសឱ្យបើកដំណើរការសាលារៀនឡើងវិញទូទាំងប្រទេសនៅឆ្នាំសិក្សា ២០២២-២០២៣ ការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន កម្មវិធីគាំទ្រផ្សេងៗ និងការចូលរួមជ្រោមជ្រែងយ៉ាងសកម្មពីសំណាក់មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ អាជ្ញាធរដែនដីជាដើម ដែលបានបង្កលក្ខណៈឱ្យសិស្សានុសិស្ស មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំ។ ទោះជាយ៉ាងណា អត្រានេះមានការធ្លាក់ចុះបន្តិចមក ៣៣,៦ភាគរយ ក្នុងឆ្នាំសិក្សា២០២១-២០២២ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ អត្រារួមនៃការសិក្សាការអប់រំកុមារតូច (អាយុ៣-៥ឆ្នាំ) របស់សិស្សប្រុស មានការកើនឡើងជាបន្តបន្ទាប់ចាប់ពី ៣៣,១ភាគរយ ក្នុងឆ្នាំសិក្សា២០២០-២០២១ ដល់ ៤២,២ ភាគរយ ក្នុងឆ្នាំសិក្សា២០២៤-២០២៥ កើន ៩,១ ភាគរយ។ អត្រារួមនៃការសិក្សាការអប់រំកុមារតូច (អាយុ៣-៥ឆ្នាំ) របស់សិស្សស្រី មានការកើនឡើងពី ៣៥,៩ភាគរយ ក្នុងឆ្នាំសិក្សា ២០២០-២០២១ ដល់ ៤៣,៣ភាគរយ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ កើន ៧,៤ភាគរយ។

### រូបភាពទី២៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ មានការកើនឡើងពី ៦១,១ភាគរយ (ស្រី ៦២,៣ភាគរយ ប្រុស ៥៨,៦ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ៧១,៤ភាគរយ (ស្រី ៧១,៩ភាគរយ ប្រុស ៧០,៩ ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥ កើនឡើង ១០,៣ភាគរយ (ស្រី ៩,៦ភាគរយ ប្រុស ១២,៣ភាគរយ) ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ការកើនឡើងការចូលរៀននេះ គឺដោយសារការពង្រីកសាលាមត្តេយ្យសិក្សាគ្រប់រូបភាព ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀនតាមតម្រូវការនៅតាមមូលដ្ឋាន កម្មវិធីគាំទ្រផ្សេងៗ និងការចូលរួមយ៉ាងសកម្មពីមាតាបិតា អ្នកអាណាព្យាបាល សហគមន៍ អាជ្ញាធរដែនដី ដែលបានបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានសេវាអប់រំកុមារតូច។

**រូបភាពទី៣៖ សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមនៃការសិក្សាការអប់រំកុមារតូច (អាយុ៣-៥ឆ្នាំ)**




សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួមនៃការសិក្សាការអប់រំកុមារតូច មានភាពល្អប្រសើរ ដោយមានការថយចុះពី ១,០៨ នៅឆ្នាំសិក្សា២០២០-២០២១ មកត្រឹម ១,០៣ នៅឆ្នាំសិក្សា២០២៤-២០២៥។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទោះបីជានៅឆ្នាំសិក្សា២០២២-២០២៣ និងឆ្នាំសិក្សា២០២៣-២០២៤ សន្ទស្សន៍យុគភាពយេនឌ័រមានទំនោរទៅលើកុមារីក៏ដោយ ក៏និន្នាការនេះបានបង្ហាញថា សិស្សស្រីចូលរៀនប្រហាក់ប្រហែលនឹងសិស្សប្រុសក្នុងរយៈពេល៥ឆ្នាំ។

## ការអប់រំបឋមសិក្សា

ឆ្នាំសិក្សា២០២៤-២០២៥ សិស្សបឋមសិក្សាមាន ២ ២៦១ ២១៦នាក់ ថយ ៤ ៥៦៧នាក់ ស្រី ១ ០៨៥ ៨៨០នាក់ ថយ ១ ០១២នាក់។ សិស្សបឋមសិក្សារដ្ឋ ២ ០៧៨ ៤០១នាក់ ថយ ១៣ ៩១៦នាក់ ស្រី ៩៩៧ ០០៣នាក់ ថយ ៥ ៧៦៤នាក់។ សិស្សបឋមសិក្សាឯកជន ១៨២ ៨១៥នាក់ កើន ៩ ៣៤៩នាក់ ស្រី ៨៨ ៨៧៧នាក់ កើន ៤ ៧៥២នាក់។ សាលាបឋមសិក្សារដ្ឋមាន ៧ ៣៩៨ ក្នុងនោះសាលាបឋមសិក្សាឧបសម្ព័ន្ធ ៥៩។ សាលារៀនឯកជនមានកម្រិតបឋមសិក្សា ៨៩០។

**រូបភាពទី៤៖ អត្រារួមនៃការសិក្សានៅបឋមសិក្សា**




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រារួមនៃការសិក្សានៅបឋមសិក្សាកើនពី ១០៣,៤ភាគរយ (ស្រី ១០២,៤ភាគរយ ប្រុស ១០៤,៣ ភាគរយ) នៅឆ្នាំសិក្សា ២០២០-២០២១ ដល់ ១១៤,៦ភាគរយ (ស្រី ១១២,៤ភាគរយ ប្រុស ១១៦,៣ភាគរយ) នៅឆ្នាំសិក្សា ២០២៤-២០២៥ កើន ១១,២ ភាគរយ (ស្រី ១០,០ ភាគរយ ប្រុស ១២,៤ ភាគរយ) ក្នុងរយៈពេល ៥ឆ្នាំ។ ការកើនឡើងនេះ គឺដោយសារផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ដែលនាំឱ្យការចុះឈ្មោះចូលរៀនរបស់កុមារលើសអាយុមានការកើនឡើង។ អត្រារួមនៃការសិក្សានៅបឋមសិក្សាសិស្សស្រីទាបជាងសិស្សប្រុសតិចតួច ចាប់ពីឆ្នាំសិក្សា២០២០-២០២១ដល់២០២៤-២០២៥ លើកលែងតែឆ្នាំសិក្សា២០២១-២០២២ ។

## រូបភាពទី៥៖ សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមនៃការសិក្សានៅបឋមសិក្សា




សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមការនៃសិក្សានៅបឋមសិក្សា មានភាពល្អប្រសើរ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ គឺនៅចន្លោះ០,៩៦ ដល់ ១,០១ ដែលបង្ហាញថាមានសន្ទស្សន៍យុគភាពយេនឌ័រ។ និន្នាការនេះ បង្ហាញថា សិស្សស្រីចូលរៀនប្រហាក់ប្រហែលនឹងសិស្សប្រុសក្នុងរយៈពេល៥ឆ្នាំ។

## រូបភាពទី៦៖ អត្រាបោះបង់ការសិក្សានៅបឋមសិក្សា




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាបោះបង់ការសិក្សានៅបឋមសិក្សាថយពី ៧,២ ភាគរយ (ស្រី ៥,៧ ភាគរយ ប្រុស ៨,៦ ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ មក ៤,១ភាគរយ (ស្រី ២,៩ភាគរយ ប្រុស ៥,២ភាគរយ) នៅឆ្នាំសិក្សា ២០២៤-២០២៥ ដែលថយចុះ ៣,១ភាគរយ (ស្រី ២,៨ភាគរយ ប្រុស ៣,៤ភាគរយ) ក្នុងរយៈពេល ៤ឆ្នាំកន្លងមក តាមរយៈកម្មវិធីផ្តល់អាហារូបករណ៍ និងអាហារតាមសាលារៀន។ អត្រាបោះបង់ការសិក្សារបស់សិស្សស្រីទាបជាងសិស្សប្រុស ក្នុងឆ្នាំសិក្សា២០២០-២០២១ និង ២០២៣-២០២៤ ប៉ុន្តែអត្រាបោះបង់សិស្សស្រីខ្ពស់ជាងសិស្សប្រុស នៅឆ្នាំសិក្សា ២០២១-២០២២ និងឆ្នាំសិក្សា ២០២២-២០២៣។

## រូបភាពទី៧៖ អត្រាត្រួតថ្នាក់នៅបឋមសិក្សា




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាត្រួតថ្នាក់នៅបឋមសិក្សាមានការថយចុះជាលំដាប់ ពី ៨,០ ភាគរយ (ស្រី ៦,១ ភាគរយ ប្រុស ៩,៨ ភាគរយ) នៅឆ្នាំសិក្សា ២០២០-២០២១ មក ៥,៤ភាគរយ (ស្រី ៣,៩ ភាគរយ ប្រុស ៦,៩ ភាគរយ) នៅឆ្នាំសិក្សា ២០២៣-២០២៤ ដែលថយចុះ ២,៦ភាគរយ (ស្រី ២,២ ភាគរយ ប្រុស ២,៩ ភាគរយ) ក្នុងរយៈពេល៤ឆ្នាំកន្លងមក។ អត្រាត្រួតថ្នាក់សិស្សស្រីទាបជាងសិស្សប្រុសក្នុងរយៈពេល៤ឆ្នាំកន្លងមក ដែលមានគម្លាតជាមធ្យម ៣,៣ភាគរយ។ ប្រការនេះបង្ហាញថា ការសិក្សារបស់សិស្សស្រី ប្រសើរជាងសិស្សប្រុស។

## រូបភាពទី៨៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាកើនពី ៨៧,៤ភាគរយ (ស្រី ៩១,៦ភាគរយ ប្រុស ៨៣,៤ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ១០១,៥ភាគរយ (ស្រី ១០៤,១ភាគរយ ប្រុស ៩៩,០ភាគរយ) នៅឆ្នាំសិក្សា ២០២៤-២០២៥។ អត្រាបញ្ចប់ការសិក្សាសិស្សស្រីខ្ពស់ជាងសិស្សប្រុសក្នុងឆ្នាំនីមួយៗ គិតជាមធ្យម ៥,៧ ភាគរយ ក្នុងរយៈពេល ៥ឆ្នាំកន្លងមក។ ការណ៍នេះ បង្ហាញថា សិស្សស្រីបានបញ្ចប់ការសិក្សាច្រើនជាងសិស្សប្រុសនៅកម្រិតបឋមសិក្សា។

## ការអប់រំមធ្យមសិក្សា

ឆ្នាំសិក្សា២០២៤-២០២៥ សិស្សមធ្យមសិក្សាបឋមភូមិសរុប ៧១២ ២៩៨នាក់ ស្រី ៣៧១ ១៨៨ នាក់។ សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋ ៦៦១ ៥០៨នាក់ ស្រី ៣៤៤ ៩០៦នាក់។ សិស្សមធ្យមសិក្សាបឋមភូមិឯកជន ៥០ ៧៩០នាក់ ស្រី ២៦ ២៨២នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិសរុប ៤៥៦ ៨០៤នាក់ ស្រី ២៥៣ ៨៦៤នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋ ៤១៣ ៣៥២នាក់ ស្រី ២៣១ ៤៩៧នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិឯកជន ៤៣ ៤៥២នាក់ ស្រី២២ ៣៦៧នាក់។ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ១ ៨២៥ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៤ និងវិទ្យាល័យ ៥៨១។ គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ៤៤២ ក្នុងនោះអនុវិទ្យាល័យ ១១៤ និងវិទ្យាល័យ ៣២៨។ ឃុំ សង្កាត់ ១០៧ ក្នុងចំណោម ១ ៦៥២ ស្មើ ៦,៤៧ ភាគរយ មិនទាន់មានអនុវិទ្យាល័យ ក្នុងនោះ រាជធានីភ្នំពេញ ៤៦សង្កាត់ មិនទាន់ត្រូវការឱ្យបង្កើតអនុវិទ្យាល័យ ខេត្តរតនគិរី ២០ឃុំ មណ្ឌលគិរី ៨ឃុំ ស្វាយរៀង ៧ឃុំ ពោធិ៍សាត់ ៤ឃុំ កោះកុង ៤ឃុំ បាត់ដំបង ៤ឃុំ ព្រះសីហនុ ៣ឃុំ កំពង់ឆ្នាំង ៣ឃុំ កំពត ២ឃុំ កណ្ដាល ២ឃុំ កំពង់ស្ពឺ ២ឃុំ ព្រះវិហារ ១ឃុំ និងក្រចេះ ១ឃុំ មិនទាន់ត្រូវការឱ្យបង្កើតអនុវិទ្យាល័យទេ ដោយសារកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ។ ដោយឡែកស្រុក ១ ក្នុងចំណោម ២០៨ នៅមិនទាន់មានវិទ្យាល័យ គឺស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ ដោយសារស្រុកមិនទាន់មានធនធានគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ទីតាំងវិទ្យាល័យបើកថ្មីពុំទាន់មានអគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសមស្របដែលតម្រូវឱ្យបើកដំណើរការសិក្សាជាបណ្ដោះអាសន្ន។

**រូបភាពទី៩៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ**




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនពី ៦០,៧ ភាគរយ (ស្រី ៦៦,៦ ភាគរយ ប្រុស ៥៥,៣ ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ៧៥,២ ភាគរយ (ស្រី ៨០,២ ភាគរយ ប្រុស ៧០,៥ ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥ កើន ១៤,៥ ភាគរយ (ស្រី ១៣,៦ ភាគរយ ប្រុស ១៥,២ ភាគរយ) ក្នុងរយៈពេល៥ឆ្នាំ។ កំណើននេះ បង្ហាញពីការយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការប្រមូលកុមារចូលរៀន។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិសិស្សស្រីខ្ពស់ជាងសិស្សប្រុសជារៀងរាល់ឆ្នាំ គិតជាមធ្យម ៩,៧ភាគរយ។

### រូបភាពទី១០៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនពី ៣២,២ ភាគរយ (ស្រី ៣២,៣ ភាគរយ ប្រុស ២៨,៥ ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ៤៤,៣ ភាគរយ (ស្រី ៥០,៥ ភាគរយ ប្រុស ៣៨,៤ ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥ កើន ១២,១ ភាគរយ (ស្រី ១៨,២ ភាគរយ ប្រុស ៩,៩ ភាគរយ) ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិសិស្សស្រីខ្ពស់ជាងសិស្សប្រុស ហើយគម្លាតនេះកាន់តែខ្ពស់ រហូតដល់ ១២,១ភាគរយ នៅឆ្នាំសិក្សា២០២៤-២០២៥។

### រូបភាពទី១១៖ សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមនៃការសិក្សានៅមធ្យមសិក្សា



សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមការនៃសិក្សានៅមធ្យមសិក្សាបឋមភូមិថយចុះពី ១,២០ មក ១,១៤ ដែលបង្ហាញពីនិន្នាការល្អខិតទៅរកសមភាពយេនឌ័រក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ទោះបីជាមានទំនោរទៅលើសិស្សស្រីក៏ដោយ។ សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមការនៃសិក្សានៅមធ្យមសិក្សាទុតិយភូមិ កើនពី ១,១៣ ដល់ ១,៣២ ដែលបង្ហាញពីនិន្នាការមិនសូវល្អ ដោយលម្អៀងទៅរកសិស្សស្រីកាន់តែខ្លាំងឡើងៗ។ ប្រការនេះបង្ហាញថា ការបន្តការសិក្សារបស់សិស្សស្រីល្អជាងសិស្សប្រុសក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ ដូច្នេះ ក្រសួងបន្តយកចិត្តទុកដាក់លើការចូលរៀនរបស់សិស្សប្រុស។

### រូបភាពទី១២៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិបានកើនពី ៤៨,១ភាគរយ (ស្រី ៥៣,៤ភាគរយ ប្រុស ៤៣,១ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ មកដល់ ៦០,៣ភាគរយ (ស្រី ៦៦,១ភាគរយ ប្រុស ៥៤,៨ ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥ កើន ១២,២ភាគរយ (ស្រី ១២,៧ ភាគរយ ប្រុស ១១,៧ ភាគរយ) ក្នុងរយៈពេល៥ឆ្នាំ។ ជារួម អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ មានភាពល្អប្រសើរ។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិសិស្សស្រីខ្ពស់ជាងសិស្សប្រុស ជាមធ្យម ១០,៣ ភាគរយ ។

### រូបភាពទី១៣៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ បានកើនពី ២៥,៣ ភាគរយ (ស្រី ២៨,៨ ភាគរយ ប្រុស ២២,០ ភាគរយ) នៅឆ្នាំសិក្សា ២០២០-២០២១ មកដល់ ៣៥,០ ភាគរយ (ស្រី ៤០,៥ ភាគរយ ប្រុស ២៩,៨ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥ កើន ៩,៧ភាគរយ (ស្រី ១១,៧ភាគរយ ប្រុស ៧,៨ ភាគរយ) ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ កំណើននេះបង្ហាញថា អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ កាន់តែល្អប្រសើរ។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិសិស្សស្រី គឺខ្ពស់ជាងសិស្សប្រុសជារៀងរាល់ឆ្នាំ ដែលនៅចន្លោះពី ៦ ទៅ១១ ភាគរយ។

### តារាងទី១៖ ចំនួន និងភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

| បរិយាយ | ចំនួន | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ២០២១-២០២២ | ៩០ ៩៥០ | ៥២ ៥១២ | ៣៨៤៣៨ | ៧២.៣៣% | ៧៧.៥១% | ៦៦.២៨% |
| ២០២២-២០២៣ | ៩៨ ៤៦០ | ៥៦ ៤៩២ | ៤១ ៩៦៨ | ៧២.៨៩% | ៧៨.០៩% | ៦៦.៩១% |
| ២០២៣-២០២៤ | ១០៦ ៣៥១ | ៦១ ៥៣០ | ៤៤ ៨២១ | ៧៩.០០% | ៨៣.២៣% | ៧៣.៨៤% |
| ២០២៤-២០២៥ | ១២២ ៤៧៣ | ៧០ ៩៩១ | ៥១ ៤៨២ | ៨៤.៥៦% | ៨៧.៩៨% | ៨០.២៤% |

ចំនួនសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលកើនពី ៩០ ៩៥០នាក់ (ស្មើ ៧២,៣៣ភាគរយ) ស្រី ៥២ ៥១២នាក់ (ស្មើ ៧៧,៥២ភាគរយ) ប្រុស ៣៨ ៤៣៨នាក់ (ស្មើ ៦៦,២៨ភាគរយ) នៅឆ្នាំសិក្សា២០២១-២០២២ ដល់ ១២២ ៤៧៣នាក់ (ស្មើ ៨៤,៥៦ ភាគរយ) ស្រី ៧០ ៩៩១នាក់ (ស្មើ ៨៧,៩៧ភាគរយ) ប្រុស ៥១ ៤៨២នាក់ (ស្មើ ៨០,២៦ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥។ ទិន្នន័យនេះបង្ហាញថា គុណភាពអប់រំកាន់តែល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។ ចំនួនសិស្សស្រីប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិច្រើនជាងសិស្សប្រុសក្នុងរយៈពេល ៤ ឆ្នាំកន្លងមក ដែលបង្ហាញថា សិស្សស្រីរៀនពូកែជាងសិស្សប្រុស។

### តារាងទី២៖ ចំនួនសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេស A, B, និង C

| បរិយាយ | ២០២០-២០២១ | | ២០២១-២០២២ | | ២០២២-២០២៣ | | ២០២៣-២០២៤ | | ២០២៤-២០២៥ | |
|---|---|---|---|---|---|---|---|---|---|---|
| និទ្ទេស A | ១ ៧៥៣ | | ១ ០៤៩ | | ១ ៦៧៣ | | ២ ២១៦ | | ៣ ០០៣ | |
| ស្រី | ១ ០៥០ | ៥៩.៩០% | ៥៥២ | ៥២.៦២% | ៩៤៧ | ៥៦.៦០% | ១ ២៨១ | ៥៧.៨១% | ១ ៦៩៤ | ៥៦.៤១% |
| ប្រុស | ៧០៣ | ៤០.១០% | ៤៩៧ | ៤៧.៣៨% | ៧២៦ | ៤៣.៤០% | ៩៣៥ | ៤២.១៩% | ១ ៣០៩ | ៤៣.៥៩% |
| និទ្ទេស B | ៥ ២១៥ | | ៧ ២៣២ | | ៦ ៩៦៤ | | ៩ ៧០១ | | ៩ ៩០១ | |
| ស្រី | ៣ ១២១ | ៥៩.៨៥% | ៤ ៤៩៨ | ៦២.២០% | ៤ ១៦៦ | ៥៩.៨២% | ៥ ៩៨៥ | ៦១.៦៩% | ៦ ១៩៨ | ៦២.៦០% |
| ប្រុស | ២ ០៩៤ | ៤០.១៥% | ២ ៧៣៤ | ៣៧.៨០% | ២ ៧៩៨ | ៤០.១៨% | ៣ ៧១៦ | ៣៨.៣១% | ៣ ៧០៣ | ៣៧.៤០% |
| និទ្ទេស C | ១១ ៦៣៤ | | ១៩ ០៥៣ | | ១៨ ៣០៨ | | ២២ ៦៧៥ | | ២៨ ៨០១ | |
| ស្រី | ៧ ២៣១ | ៦២.១៥% | ១១ ៧៧៧ | ៦១.៨១% | ១១ ៥១៩ | ៦២.៩២% | ១៤ ២២០ | ៦២.៧១% | ១៨ ៥៧៨ | ៦៤.៥០% |
| ប្រុស | ៤ ៤០៣ | ៣៧.៨៥% | ៧ ២៧៦ | ៣៨.១៩% | ៦ ៧៨៩ | ៣៧.០៨% | ៨ ៤៥៥ | ៣៧.២៩% | ១០ ២២៣ | ៣៥.៥០% |

ចំនួនសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេស A, B, C កើនឡើងយ៉ាងខ្លាំង ដោយកើនរៀងគ្នា និទ្ទេស A ១ ៧៥៣ នាក់ និទ្ទេស B ៥ ២១៥ នាក់ និងនិទ្ទេស C ១១ ៦៣៤ នាក់ នៅឆ្នាំសិក្សា ២០២០-២០២១ ដល់ និទ្ទេស A ៣ ០០៣ នាក់ និទ្ទេស B ៩ ៩០១ នាក់ និងនិទ្ទេស C ២៨ ៨០១ ឆ្នាំសិក្សា ២០២៤-២០២៥។ សិស្សស្រីទទួលបាននិទ្ទេស A, B, C ច្រើនជាងសិស្សប្រុស ក្នុងរយៈពេល៥ឆ្នាំកន្លងមក។ ដូចនេះ ក្រសួង បន្តយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការលើកកម្ពស់គុណភាពអប់រំ ជាពិសេស ការផ្តល់យន្តការគាំទ្រដល់សិស្សប្រុស ដើម្បីធានាបានគុណភាពអប់រំប្រកបដោយសមធម៌នៅកម្រិតមធ្យមសិក្សា។

## ការអប់រំឧត្តមសិក្សា

ឆ្នាំសិក្សា២០២៣-២០២៤ និស្សិតកំពុងសិក្សានៅឧត្តមសិក្សាមាន ៣១៦ ១០៥នាក់ កើន ៣១ ៥០៦ នាក់ ស្មើ ១១,០៧ភាគរយ ស្រី ១៦៥ ៩៩៤នាក់ ស្មើ ៥២,៥១ភាគរយ កើន ១៧ ២៣៧នាក់ ស្មើ ១១,៥៩ ភាគរយ។ គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១៩៤ កើន៥ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៧៩ និងគ្រឹះស្ថានឧត្តមសិក្សាឯកជន ១១៥ កើន៥ ដែលមានទីតាំងស្ថិតនៅ ២៥ ខេត្ត រាជធានី។ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ន១៧។ គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន ៩៤ កើន៤ និងមានទីតាំងស្ថិតនៅ ២២ខេត្ត រាជធានី ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ១៧ គ្រឹះស្ថានឧត្តមសិក្សាឯកជន ៧៧ កើន៤ និងសាខា ៤៥ កើន៥។

**រូបភាពទី១៤៖ អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ)**




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ) កើនពី ១៣,៨ ភាគរយ ក្នុងឆ្នាំសិក្សា ២០២០-២០២១ ដល់ ១៩,១ភាគរយ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ កើន ៥,៣ ភាគរយ។ អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ) ស្រី កើនពី ១១,៩ភាគរយ ក្នុងឆ្នាំសិក្សា២០២០-២០២១ ដល់ ២០,៨ភាគរយ ក្នុងឆ្នាំសិក្សា២០២៣-២០២៤ កើន ៨,៩ភាគរយ ចំណែកឯអត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ) ប្រុស កើនតិចតួចពី ១៧,២ភាគរយ ក្នុងឆ្នាំសិក្សា២០២០-២០២១ ដល់ ១៧,៤ភាគរយ ក្នុងឆ្នាំសិក្សា២០២៣-២០២៤។ ខណៈអត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ) សម្រាប់និស្សិតប្រុសខ្ពស់ជាងនិស្សិត

ស្រីនៅឆ្នាំសិក្សា ២០២០-២០២១ និង ២០២១-២០២២ ហើយអត្រានេះសម្រាប់និស្សិតស្រី ខ្ពស់ជាងនិស្សិតប្រុស វិញនៅឆ្នាំសិក្សា២០២២-២០២៣ និង២០២៣-២០២៤។

### រូបភាពទី១៥៖ សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ)




សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមនៃការសិក្សានៅឧត្តមសិក្សានៅចន្លោះ ០,៦៧-១,២០ ក្នុងរយៈពេល ៤ឆ្នាំកន្លងមក។ នៅឆ្នាំសិក្សា២០២០-២០២១ និង២០២១-២០២២ សន្ទស្សន៍យុគភាពយេនឌ័រអត្រារួមនៃការសិក្សានៅឧត្តមសិក្សាបានបង្ហាញថា ការចូលរៀនរបស់និស្សិតប្រុសប្រសើរជាងនិស្សិតច្រើន ក៏ប៉ុន្តែពីរឆ្នាំសិក្សាទៀត គឺការចូលរៀនរបស់និស្សិតស្រីបានប្រសើរជាង។ ការណ៍នេះ បង្ហាញពីការប្រែប្រួលគួរឱ្យកត់សម្គាល់នៅបច្ចុប្បន្ននេះនិស្សិតស្រីបន្តការសិក្សានៅឧត្តមសិក្សាច្រើនជាងនិស្សិតប្រុស។

### រូបភាពទី១៦៖ ភាគរយនិស្សិតកំពុងសិក្សាមុខជំនាញ ស្ទែមនៅឧត្តមសិក្សា




*ប្រភពទិន្នន័យ៖ នាយកដ្ឋានគ្រប់គ្រងឧត្តមសិក្សា*

ភាគរយនិស្សិតកំពុងសិក្សាមុខជំនាញស្ទែមនៅឧត្តមសិក្សាកើនពី ៣០,៤ភាគរយ (ស្រី ១៧,៥ ភាគរយ ប្រុស ៤៥,៥ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ៣៣,៨ភាគរយ (ស្រី ២៣,៣ភាគរយ ប្រុស ៤៧,៩ភាគរយ)នៅឆ្នាំសិក្សា២០២៣-២០២៤។ ភាគរយនិស្សិតប្រុសកំពុងសិក្សាមុខជំនាញស្ទែម គឺខ្ពស់ខ្លាំងជាងនិស្សិតស្រី ដែលមាន ២៤,៥ភាគរយ នៅឆ្នាំសិក្សា២០២៣- ២០២៤។ លទ្ធផលនេះ បង្ហាញពីផលជះ

វិជ្ជមាននៃកិច្ចខិតខំអនុវត្តគោលនយោបាយ និងសកម្មភាពនានារបស់ក្រសួង ក្នុងការជំរុញ គាំទ្រ និងវិនិយោគលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

### រូបភាពទី១៧៖ សន្ទស្សន៍យុគភាពយេនឌ័រការចូលរៀនមុខជំនាញស្ទែមនៅឧត្តមសិក្សា




សន្ទស្សន៍យុគភាពយេនឌ័រការចូលរៀនជំនាញស្ទែមនៅឧត្តមសិក្សា គឺនៅចន្លោះ ០,៣៨-០,៤៩ ដែលបង្ហាញថា ភាគរយនិស្សិតប្រុសចូលរៀនមុខជំនាញស្ទែមខ្ពស់ជាងនិស្សិតនារី ក្នុងរយៈពេល៤ឆ្នាំកន្លងមក។ ដូច្នេះ ក្រសួងបន្តយកចិត្តទុកដាក់បង្កើនការចូលរៀនរបស់និស្សិតនារី លើមុខជំនាញស្ទែម។

## ការអប់រំក្រៅប្រព័ន្ធ

ការអនុវត្តការងារអប់រំក្រៅប្រព័ន្ធ រួមមានកម្មវិធី ៖ អក្ខរកម្មវិជ្ជាជីវៈ, ក្រោយអក្ខរកម្ម, ចូលរៀនឡើងវិញ, បង្កើនប្រាក់ចំណូល, សមមូលបឋមសិក្សា, សមមូលមធ្យមសិក្សាបឋមភូមិ និងបំពេញវិជ្ជា។

### រូបភាពទី១៨៖ អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង បានកើនឡើងពី ៨២,៥ ភាគរយ (ស្រី ៧៨,១ ភាគរយ ប្រុស ៨៧,៣ ភាគរយ) នៅឆ្នាំ២០២០-២០២១ ដល់ ៨៧,៤ ភាគរយ (ស្រី ៨៤,១ ភាគរយ ប្រុស ៩២,៩៤ ភាគរយ) នៅឆ្នាំសិក្សា២០២៤-២០២៥ កើន ៤,៩ភាគរយ (ស្រី ៦ ភាគរយ ប្រុស ៥,៦៤ ភាគរយ)។ ជារៀងរាល់ឆ្នាំ ក្រសួងបានប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា ដែលជាកម្លាំងចលករជួយជំរុញឱ្យកម្មវិធីនេះកាន់តែមានប្រសិទ្ធភាព។

### រូបភាពទី១៩៖ សន្ទស្សន៍យុគភាពយេនឌ័រអត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង




ចាប់ពីឆ្នាំសិក្សា២០២០-២០២១ ដល់ឆ្នាំសិក្សា២០២៤-២០២៥ សន្ទស្សន៍យុគភាពយេនឌ័រអត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង គឺនៅចន្លោះ ០,៨៩ ដល់ ០,៩៣ ដែលមានទំនោរទៅលើបុរសបន្តិចបន្តួច។ និន្នាការនេះ នឹងឆ្ពោះទៅរកភាពប្រសើរឡើង ខណៈពេលក្រសួង និងដៃគូអភិវឌ្ឍបាននិងកំពុងលើកកម្ពស់កម្មវិធីអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង ដោយឆ្លើយតបនឹងយេនឌ័រ។

## ការអភិវឌ្ឍយុវជន

ក្រសួងបានរៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រ ដើម្បីជួយគាំទ្រដល់ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សារបស់យុវជន និងកុមារ សំដៅបណ្តុះស្មារតីស្រឡាញ់ការសិក្សា អភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ក្នុងបរិបទសតវត្សរ៍ទី២១។

### រូបភាពទី២០៖ ចំនួនសមាជិកក្រុមប្រឹក្សាកុមារកម្ពុជា




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

ក្រុមប្រឹក្សាកុមារកម្ពុជាបានកំណត់យកសិស្សថ្នាក់ទី៤-៩ ចូលរួមក្នុងក្រុមប្រឹក្សាកុមារកម្ពុជា។ ចំនួនកុមារចូលរួមក្នុងក្រុមប្រឹក្សាកុមារកម្ពុជាបានថយចុះពី ១៥៨ ៣៦០២នាក់ នៅឆ្នាំសិក្សា២០២០-២០២១ ដល់ ១ ៥៦៣ ២៨៤នាក់នៅឆ្នាំសិក្សា២០២២-២០២៣ ប៉ុន្តែបានកើនដល់ ១ ៦៣១ ៩០២នាក់នៅឆ្នាំសិក្សា ២០២៤-

២០២៥ ដែលបង្ហាញពីស្ថានភាពការចូលរួមរបស់សិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សានានាក្នុងដំណើរការនៃក្រុមប្រឹក្សាកុមារកម្ពុជា រួមទាំងកំណើនគ្រឹះស្ថានសិក្សា ការអនុវត្តកម្មវិធីបំណិនជីវិត និងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ។ ជារួម ចំនួនកុមារីចូលរួមក្នុងក្រុមប្រឹក្សាកុមារកម្ពុជា ប្រហាក់ប្រហែលគ្នានឹងកុមារា។

### រូបភាពទី២១៖ សន្ទស្សន៍យុគភាពយេនឌ័រនៃចំនួនសមាជិកក្រុមប្រឹក្សាកុមារកម្ពុជា




ចាប់ពីឆ្នាំសិក្សា២០២០-២០២១ ដល់ ២០២៤-២០២៥ បង្ហាញថា មានសន្ទស្សន៍យុគភាពយេនឌ័រនៃចំនួនសមាជិកក្រុមប្រឹក្សាកុមារកម្ពុជា ក្នុងរង្វង់ ១,០១ លើកលែងតែឆ្នាំសិក្សា២០២១-២០២២ សន្ទស្សន៍យុគភាពយេនឌ័រ គឺ ១,០៦។ និន្នាការនេះបង្ហាញថា ការចូលរួមក្នុងក្រុមប្រឹក្សាកុមារកម្ពុជារបស់កុមារា និងកុមារីប្រហាក់ប្រហែលគ្នា។

### រូបភាពទី២២៖ ចំនួនសមាជិកក្រុមប្រឹក្សាយុវជនកម្ពុជា




*ប្រភពទិន្នន័យ៖ សន្និបាតអប់រំ*

ក្រុមប្រឹក្សាយុវជនកម្ពុជាបានកំណត់យកសិស្សថ្នាក់ទី១០-១២ចូលរួមក្នុងក្រុមប្រឹក្សាយុវជនកម្ពុជា។ ចំនួនយុវជនបានចូលរួមក្នុងក្រុមប្រឹក្សាយុវជនកម្ពុជាបានកើនឡើងពី ៣៥៧ ៧៨៦នាក់នៅឆ្នាំសិក្សា ២០២០-២០២១ ដល់ ៤១៣ ៣៥២នាក់ នៅឆ្នាំសិក្សា២០២៤-២០២៥។

### រូបភាពទី២៣៖ សន្ទស្សន៍យុគភាពយេនឌ័រនៃចំនួនសមាជិកក្រុមប្រឹក្សាយុវជនកម្ពុជា




ចាប់ពីឆ្នាំសិក្សា២០២០-២០២១ ដល់ ២០២៤-២០២៥ បង្ហាញថា សន្ទស្សន៍យុគភាពយេនឌ័រនៃចំនួនសមាជិកក្រុមប្រឹក្សាយុវជនកម្ពុជា គឺចន្លោះ ១,១៧ ដល់ ១,២៧។ និន្នាការនេះបង្ហាញថា សមាជិកក្រុមប្រឹក្សាយុវជន គឺមានទំនោរទៅលើស្រី ក្នុងរយៈពេល ៥ឆ្នាំកន្លងមក។

**ចំនួនយុវជន-យុវនារីដែលបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន** មានដូចជា ការគិតបែបត្រិះរិះពិចារណា ការធ្វើការងារជាក្រុម ការច្នៃប្រឌិត ការដោះស្រាយបញ្ហា ភាពជាអ្នកដឹកនាំ ការប្រាស្រ័យទាក់ទង ការងារស្ម័គ្រចិត្ត ជំនាញភាសា អក្ខរកម្មឌីជីថល ជំនាញសារព័ត៌មាន និងភាពជាសហគ្រិនដែលមានគោលដៅលើកកម្ពស់ទំនួលខុសត្រូវរបស់ពលរដ្ឋ ការបណ្ដុះស្មារតីស្នេហាជាតិ សាមគ្គីភាព និងការដឹងគុណចំពោះសន្តិភាព និងការអភិវឌ្ឍសង្គមក្នុងចំណោមយុវជនកម្ពុជា។ កម្មវិធីសំខាន់ៗមួយចំនួនទៀតដូចជា ១) កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ ២) កម្មវិធីយុវជន២១ «សហគ្រិនបែបឌីជីថល» ៣) កម្មវិធីធុរកិច្ចជាតិសម្រាប់យុវជន ៤) កម្មវិធីអ្នកនាំសារសន្តិភាពដើម្បីសហគមន៍ខ្ញុំ ៥)សិក្ខាសាលាផ្លាស់ប្ដូរបទពិសោធន៍លើបំណិនបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ៦) អ្នកនាំសារសន្តិភាពដើម្បីសហគមន៍ខ្ញុំ ៧) កម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ៨) កម្មវិធីការប្រកួតប្រជែងផែនការអាជីវកម្ម និង ៩) កម្មវិធីអប់រំសេមមូលកម្រិតមូលដ្ឋាន។

## ការអប់រំកាយ និងកីឡា

ឆ្នាំសិក្សា២០២៤-២០២៥ ក្រសួងបានរៀបចំការប្រកួតកីឡាថ្នាក់ជាតិ ដែលមានសិស្សបឋមសិក្សា និងប្រតិភូកីឡានិងកីឡាករ ៣ ០២៦នាក់ ស្រី ១០១៥នាក់ លើ ១៣ប្រភេទកីឡា និងសិស្សមធ្យមសិក្សាមានប្រតិភូកីឡានិងកីឡាករ ៣ ៦២០នាក់ ស្រី ១ ២៦១នាក់ លើ១៤ប្រភេទកីឡា។

ក្នុងការលើកកម្ពស់សមត្ថភាពគ្រូបង្វឹក កីឡាករ និងកីឡាការិនី ៖ ក្រសួងបានធ្វើការប្រមូលផ្ដុំក្រុមថ្នាល ដែលមានគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនីថ្នាលចំនួន ១៣៧នាក់ ស្រី ៣៩នាក់ មកហ្វឹកហាត់លើ ១៩ប្រភេទកីឡា និងក្រុមយុវជនមានពិការភាពថ្នាល ចំនួន៣០នាក់ ស្រី១១នាក់ និងបានធ្វើការប្រមូលផ្ដុំក្រុមកីឡាជម្រើសជាតិឈុតធំដែលមានគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនីចំនួន ៧៣៦

នាក់ ស្រី ២០៣នាក់ មកហ្វឹកហាត់លើ ៤០ប្រភេទកីឡា សម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេម លើកទី៣៣ និងការប្រកួតជាលក្ខណៈអន្តរជាតិនានា និងប្រមូលផ្ដុំក្រុមជម្រើសជាតិជនមានពិការភាព គ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនី ជនពិការ ចំនួន១១២នាក់ ស្រី៣៦នាក់ មកហ្វឹកហាត់លើ១០ប្រភេទកីឡាសម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាប៉ារ៉ាហ្គេមលើកទី១៣ និងការប្រកួតជាលក្ខណៈអន្តរជាតិនានា។

### តារាងទី៣៖ លទ្ធផលនៃការប្រកួតកីឡាលក្ខណៈអន្តរជាតិ

| ប្រភេទកីឡា | ប្រតិភូ | កីឡាករ | កីឡាការិនី | មេដាយ | | | សរុប |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | |
| ការប្រកួតជើងឯកពិភពលោក | ១១ | ២២ | ១០ | ០ | ០ | ០ | ០ |
| ការប្រកួតជើងឯកអាស៊ី | ២១ | ៤៥ | ២៧ | ១០ | ៥ | ២ | ១៧ |
| ការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ | ៥ | ១២ | ៧ | ៦ | ៣ | ៤ | ១៣ |
| ការប្រកួតកីឡាបើកទូលាយ | ១៧ | ២៤ | ១៦ | ៣ | ៣ | ៣ | ៩ |
| សរុប | | | | ១៩ | ១១ | ៩ | ៣៩ |

*ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានកីឡា*

### តារាងទី៤ ៖ ការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ

| ឆ្នាំប្រកួត | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
| ចំនួនប្រភេទកីឡា | ៨ | ១០ | ១២ | ១៣ |
| ចំនួនវិញ្ញាសាសរុប | ៣៤ | ៥១ | ៦៥ | ៦៨ |
| ចំនួនវិញ្ញាសានារី | ១៥ | ២០ | ៣១ | ៣៦ |
| ចំនួនអ្នកចូលរួមសរុប | ១៦៣៧ | ២៦០០ | ២៩៦០ | ៣០២៦ |
| ចំនួនកីឡាការិនី | ៤៣១ | ៨៦៩ | ១០០៤ | ១០១៥ |

### តារាងទី៥ ៖ ការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ

| ឆ្នាំប្រកួត | ២០២៣ | ២០២៥ |
|---|---|---|
| ចំនួនប្រភេទកីឡា | ១២ | ១៤ |
| ចំនួនវិញ្ញាសាសរុប | ១០៥ | ១២៤ |
| ចំនួនវិញ្ញាសានារី | ៥០ | ៦២ |
| ចំនួនអ្នកចូលរួមសរុប | ៣២៥៧ | ៣៦២០ |
| ចំនួនកីឡាការិនី | ១១៦៩ | ១២៦១ |

### តារាងទី៦ ៖ ការប្រកួតកីឡានិស្សិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេស

| ឆ្នាំប្រកួត | ២០២២ | ២០២៤ |
|---|---|---|
| ចំនួនប្រភេទកីឡា | ១២ | ១៣ |
| ចំនួនវិញ្ញាសាសរុប | ៨៨ | ១០៣ |
| ចំនួនវិញ្ញាសានារី | ៤២ | ៤៩ |
| ចំនួនអ្នកចូលរួមសរុប | ១៦៣១ | ១៧៦៤ |
| ចំនួនកីឡាការិនី | ៣៣៤ | ៣៩១ |

### តារាងទី៧ ៖ ការប្រកួតកីឡាជាតិ និងកីឡាជាតិជនពិការ

| ឆ្នាំប្រកួត | ២០១៦ | ២០១៨ | ២០២២ | | ២០២៤ | |
|---|---|---|---|---|---|---|
| | | | កីឡាជាតិ | ជនពិការ | កីឡាជាតិ | ជនពិការ |
| ចំនួនប្រភេទកីឡា | ១៤ | ២៧ | ៣៨ | ៧ | ៣៦ | ១៣ |
| ចំនួនវិញ្ញាសាសរុប | ១៧២ | ២៧៨ | ៣៥៦ | ៤៩ | ៣២៨ | ៥៥ |
| ចំនួនវិញ្ញាសានារី | ៥៧ | ៨២ | ១២៧ | ១២ | ១០២ | ១៨ |
| ចំនួនអ្នកចូលរួមសរុប | ២៦៣៧ | ៤០២៤ | ៤៧៧៣ | ២២២ | ៥៣៣៩ | ៤២១ |
| ចំនួនកីឡាការិនី | ៦០៩ | ៩៩៩ | ១២៥៨ | ៥៥ | ១៣៩៨ | ៥៧ |

#### អន្តរាគមន៍ចម្បងៗដើម្បីលើកកម្ពស់យេនឌ័រក្នុងវិស័យអប់រំ

សមិទ្ធផលទាំងនេះសម្រេចបាន តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងអន្តរាគមន៍ដោយផ្ទាល់និងប្រយោល ក្នុងគោលបំណងលើកកម្ពស់កុមារី និងស្ត្រី នៅក្នុងអនុវិស័យសំខាន់ៗ និងអន្តរអនុវិស័យដូចខាងក្រោម ៖

- ការសាងសង់សាលារៀននៅកាន់តែជិតផ្ទះប្រជាជន ដើម្បីបង្កលក្ខណៈឱ្យសិស្សមកពីគ្រួសារក្រីក្របានចូលរៀន ជាពិសេសកុមារី ដើម្បីកាត់បន្ថយចំណាយ និងសុវត្ថិភាពនៃការធ្វើដំណើរ
- ការសាងសង់បន្ទប់ទឹក និងបង្គន់អនាម័យដាច់ដោយឡែកសម្រាប់ សិស្សស្រី សិស្សប្រុស និងជម្រាលសម្រាប់សិស្សមានពិការភាព ជាពិសេស នៅកម្រិតមធ្យមសិក្សា ដើម្បីជំរុញដល់ការមកសិក្សាឱ្យបានទៀងទាត់
- ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្ស-និស្សិត និងគរុសិស្សជានារីស្នាក់នៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន វិទ្យាល័យចំណេះទូទៅ វិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស និងសាកលវិទ្យាល័យ
- ការអនុវត្តកម្មវិធីសាលាកុមារមេត្រី និងការបង្កើតកម្មវិធីទីប្រឹក្សាកុមារីនៅតាមសាលារៀន
- ការលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការអប់រំស្ត្រី ដែលការវិនិយោគតាំងពីម្តាយរហូតដល់កូន ព្រមទាំងយកចិត្តទុកដាក់លើផ្នត់គំនិតរបស់សង្គមចំពោះកូនស្រី

- ការផ្តល់អាហារូបករណ៍សម្រាប់សិស្សអាទិភាពទូទៅ សិស្សពូកែ អាទិភាពនារី អាទិភាពក្រីក្រ អាទិភាពតំបន់ដាច់ស្រយាល និងសិស្សមានពិការភាព ជាពិសេសសិស្សនារីឱ្យបានយ៉ាងតិច ៦០% នៃចំនួនសិស្សទទួលអាហារូបករណ៍បានចូលរៀននៅឧត្តមសិក្សា
- ការអភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សាគោល សម្ភារសិក្សា ការកែលម្អសកម្មភាពបង្រៀន និងរៀនឱ្យមានការទាក់ទាញ ជាពិសេសការលើកកម្ពស់ស្ត្រី កុមារីដោយគ្មានការរើសអើងចំពោះភេទ
- ការរៀបចំកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសលើមុខជំនាញ គណនេយ្យ ទេសចរណ៍ និងកែច្នៃអាហារ ដើម្បីទាក់ទាញសិស្សស្រីចូលរៀន
- ការពង្រីកការអប់រំបច្ចេកទេស និងអប់រំបំណិនជីវិតនៅមធ្យមសិក្សា ក្នុងគោលបំណងផ្តល់ជំនាញដែលចាំបាច់សម្រាប់ជីវិតប្រចាំថ្ងៃដែលមានប្រយោជន៍ ជាពិសេសដល់សិស្សស្រី ទាំងពេលកំពុងសិក្សា និងទាំងក្នុងករណីមិនអាចបន្តការសិក្សាទៅថ្នាក់ខ្ពស់បាន
- ការបញ្ចូលកម្មវិធីបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូគ្រប់កម្រិត និងការបំប៉នគ្រូឧទ្ទេស គ្រូបង្រៀន និងអ្នកគ្រប់គ្រងស្តីពីចំណេះដឹងយេនឌ័រ ការបញ្ជ្រាបយេនឌ័រក្នុងការបង្រៀន និងរៀន និងការងារគ្រប់គ្រងអប់រំ
- ការបំប៉នស្តីពី ភាពឆាប់ចាប់អារម្មណ៍លើយេនឌ័រក្នុងការងារអប់រំជូនគ្រូឧទ្ទេស និងនាយក នាយករងនៅតាមសាលាគរុកោសល្យ (វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម និងសាលាគរុកោសល្យ និងវិក្រឹតការ)
- ការបំប៉នស្តីពីការគ្រប់គ្រងសាលារៀនជូននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាដោយផ្តោតលើខ្លឹមសារស្តីពី យេនឌ័រនិងការអភិវឌ្ឍសាលារៀន យេនឌ័រនិងអំពើជួញដូរមនុស្ស យេនឌ័រនិងអំពើហិង្សាក្នុងគ្រួសារ យេនឌ័រនិងសុខភាព យេនឌ័រនិងការប្រែប្រួលអាកាសធាតុ
- ការបំប៉នស្តីពីការបង្កើត ការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធីទីប្រឹក្សាសាលារៀន ជូននាយក នាយករងសាលា ទីប្រឹក្សាសាលារៀន គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យ
- ការផ្តល់ការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺឆ្លងផ្សេងៗទៀត
- ការផ្តល់អាទិភាពដល់កុមារី និងស្ត្រី ក្នុងការប្រកួតប្រជែង និងការជ្រើសរើសនានា។

## ២.២ ការបង្កើនសមតាពយេនឌ័រនៅក្នុងការអប់រំ និងការផ្តល់ភាពអង់អាចក្លាហានដល់ស្ត្រីក្នុងការងារគ្រប់គ្រង

ក្រសួងបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ២០២១-២០២៥ ដោយសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើនសមភាពយេនឌ័រនៅក្នុងវិស័យអប់រំគ្រប់កម្រិត និងផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការងារភាពជាអ្នកដឹកនាំ និងគ្រប់គ្រង។ សមិទ្ធផលសម្រេចបានដូចមាននៅក្នុងតារាងខាងក្រោម ៖

## តារាងទី៨ ៖ វឌ្ឍនភាពសម្រេចបាន ការបង្កើនសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចក្លាហានដល់ស្ត្រី

| សូចនាករ | ឯកតា | ឆ្នាំមូលដ្ឋាន | ជាក់ស្តែង | | | | | ចំណុចដៅ | និន្នាការ |
|---|---|---|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៥ | |
| **ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រងនៅថ្នាក់កណ្តាល** | | | | | | | | | |
| អគ្គនាយក សាកលវិទ្យាធិការ | % | ១២.៥ | ១២.៨ | ១២.៩ | ១៣.០ | ៦.៦៣ | ១៣.៣៣ | ១៣.១ | ↑ |
| អគ្គនាយករង សាកលវិទ្យាធិការរង | % | ៦.០ | ៦.៩ | ៧.៥ | ៨.០ | ១០.៦៣ | ១០.០០ | ១០.០ | ↑ |
| ប្រធាននាយកដ្ឋាន | % | ១១.១ | ៧.៧ | ៨.៣ | ៩.០ | ១០.០០ | ២១.២១ | ១២.៧ | ↑ |
| អនុប្រធាននាយកដ្ឋាន | % | ១៨.២ | ១៩.៧ | ១៩.៨ | ២០.០ | ១៨.២៤ | ១៦.០៦ | ២៣.០ | ↓ |
| ប្រធានការិយាល័យ | % | ១៩.៦ | ២០.៨ | ២០.៩ | ២១.០ | ១៦.៥៣ | ១៨.៣៣ | ២៤.១ | ↓ |
| អនុប្រធាន ការិយាល័យ | % | ២៤.៩ | ២៤.៩ | ២៥.៤ | ២៦.០ | ២៦.៩៥ | ២៦.៣៤ | ២៩.៦ | ↓ |
| **ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត** | | | | | | | | | |
| ប្រធានមន្ទីរ | % | ៤.០ | ៦.០ | ៧.០ | ៨.០ | ៤.០០ | ៤.០០ | ១០.០ | ↓ |
| អនុប្រធានមន្ទីរ | % | ២៣.៥ | ២៣.៤ | ២៣.៧ | ២៤.០ | ២៦.០២ | ២៦.៣៨ | ២៧.៦ | → |
| ប្រធានការិយាល័យ | % | ១២.៩ | ១៤.៩ | ១៥.៤ | ១៦.០ | ១២.៨៦ | ១៤.០២ | ១៥.៧ | ↓ |
| អនុប្រធាន ការិយាល័យ | % | ២៣.៤ | ២៣.៨ | ២៤.៤ | ២៥.០ | ២៨.០៣ | ២២.៨៩ | ២៧.៣ | ↓ |
| **ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ** | | | | | | | | | |
| ប្រធានការិយាល័យ | % | ៥.៤ | ៧.៣ | ៨.២ | ៩.០ | ៥.១២ | ៥.០២ | ១៥.៣ | ↓ |
| អនុប្រធាន ការិយាល័យ | % | ១៤.១ | ១៣.៨ | ១៤.៤ | ១៥.០ | ១៨.២៩ | ១៩.៦៣ | ២៣.៨ | ↓ |
| **ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងនៅថ្នាក់សាលារៀន** | | | | | | | | | |
| នាយិកា | % | ១៣.៥ | ១៣.២ | ១៤.១ | ១៥.០ | ១៤.៤៧ | ១៤.៦៣ | ១៧.២ | ↓ |
| នាយិការង | % | ២១.៥ | ២៣.១ | ២៤.១ | ២៥.០ | ២៣.៤៧ | ២៣.៥៨ | ២៦.៨ | ↓ |
| **ភាគរយគ្រូបង្រៀនជាស្ត្រី** | | | | | | | | | |
| ទូទាំងប្រទេស | % | ៤៦.២ | ៤៧.៩ | ៤៨.៩ | ៥០.០ | ៥៣.២៨ | ៥៣.៤៦ | ៥០.០ | ↑ |
| ទីប្រជុំជន | % | ៥១.៧ | ៥១.៧ | ៥៣.៩ | ៥៦.០ | ៥៤.៥១ | ៥៤.៩០ | ៦០.០ | ↓ |
| ជនបទ | % | ៤៤.៩ | ៤៧.៨ | ៤៨.៩ | ៥០.០ | ៥២.៧១ | ៥៣.០១ | ៥០.០ | ↑ |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

*ប្រភពទិន្នន័យ៖ នាយកដ្ឋានធនធានមនុស្ស*

## ស្ថានភាពចំនួនស្ត្រីជាមន្ត្រីរាជការជានារី

ឆ្នាំ២០២៥ បុគ្គលិកអប់រំគ្រប់កម្រិតសរុប ១២៤ ៥១៧នាក់ ស្រី ៥៩ ១៦៥នាក់ ស្មើនឹង៤៧,៥១ ភាគរយ ក្នុងនោះ ថ្នាក់ជាតិ ៤ ៩៧៨នាក់ ស្រី ១ ៦៥៨នាក់ និងថ្នាក់ក្រោមជាតិ ១១៩ ៥៣៩នាក់ ស្រី ៥៧ ៥០៧នាក់។ ក្រសួងបានប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ៧០៤នាក់ ស្រី ២៨៥នាក់ ក្នុងនោះថ្នាក់ជាតិ ៤៦១នាក់ ស្រី ១៨៦នាក់ និងថ្នាក់ក្រោមជាតិ ២៤៣នាក់ ស្រី ៩៩នាក់។

គ្រូមត្តេយ្យសិក្សា ៤ ១០៧នាក់ ស្រី ៤ ០០៣នាក់ គ្រូបឋមសិក្សា ៥៣ ១៥៣នាក់ ស្រី ២៩ ១៤៦នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋាន ៤៣ ៣៤៦នាក់ ស្រី ១៨ ៨៣៩នាក់ គ្រូអប់រំកាយនិងកីឡា ២ ៥៧៤នាក់ ស្រី ៥៣០នាក់ គ្រូបង្រៀនកម្រិតឧត្តម ១៩ ៣៣១នាក់ ស្រី ៦ ១៥៩នាក់ គ្រូបង្រៀនកម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ១ ៦៧១នាក់ ស្រី ៤៣៧នាក់ អធិការបឋម ៤០នាក់ ស្រី ៦នាក់ អធិការមធ្យម និងអធិការអប់រំ ២៩៥នាក់ ស្រី ៤៥នាក់។

ក្រសួងបាននិងកំពុងបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតឆ្នាំសិក្សា២០២៣-២០២៤ ចំនួន ៣ ២២៧ នាក់ ស្រី ១ ៩៦៩នាក់។

ក្រសួងបានធ្វើវិក្រឹតការ ដូចជា៖

- ការពង្រីកវិសាលភាពអនុវត្តប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅ ១០០សាលារៀន ក្នុងខេត្តគោលដៅ ៥
- សិក្ខាកាមចុះឈ្មោះក្នុងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ១៤ ២៣៧នាក់ ស្រី ៨៤១៥នាក់
- សិក្ខាកាមទទួលបានក្រេឌីតក្នុងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ៨ ៥១៩នាក់ ស្រី ៥ ២៦៦នាក់
- ការផ្តល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពអ្នកផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ៥អង្គភាព
- ការផ្តល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពដល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ៤៣ សកម្មភាព
- នាយកសាលាមធ្យមសិក្សាចំណោះទូទៅ ៥៤១នាក់ ស្រី ១៦៤នាក់ បានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រង
- គ្រូបង្រៀនបានចូលរួមកម្មវិធីអភិវឌ្ឍសមត្ថភាពឱ្យទទួលបានសញ្ញាបត្របរិញ្ញាបត្រ ១ ៧២៨ នាក់ ស្រី ៩៨៧នាក់ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ១៤៤ នាក់ ស្រី ៧២នាក់
- ការបំប៉នគ្រូបង្រៀនកម្រិតបឋមដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន បញ្ចប់ជំនាន់ទី១៣ វេនទី២ ចំនួន ១ ៤៣៤នាក់ ស្រី ៦៥៩នាក់
- ការបញ្ជូនបុគ្គលិកអប់រំចំនួន ១៩នាក់ ស្រី ៩នាក់ ចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់អ្នកអប់រំវ័យក្មេងលើប្រធានបទ «រដ្ឋបាលអប់រំសម្រាប់ការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា»នៅជប៉ុន
- គណៈគ្រប់គ្រងសាលារៀនចំណោះទូទៅ និងគ្រូបង្រៀន ៦៩០នាក់ ស្រី ២៤៩នាក់ បានចូលរួមវគ្គបំប៉នរយៈពេលខ្លីស្តីពី ការគ្រប់គ្រងឯកទេសតាមមុខវិជ្ជា និងវិធីសាស្ត្របង្រៀន។

## នាគរយស្ត្រីដែលបានតែងតាំងក្នុងរចនាសម្ព័ន្ធ និងការធ្វើសេចក្តីសម្រេចចិត្ត

ឆ្នាំ២០២៥ អ្នកគ្រប់គ្រងនៅថ្នាក់ជាតិ (ចាប់ពីអនុប្រធានការិយាល័យរហូតដល់អគ្គនាយក/សកលវិទ្យាធិការ) មាន ១០១០នាក់ ស្រី ២២០នាក់ ត្រូវជា ២១,៧៨ ភាគរយ។

អ្នកគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ (ចាប់ពីអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដល់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត) មាន ១ ៤១៤ នាក់ ស្រី ២៧៦ នាក់ ត្រូវជា ១៩,៥១ ភាគរយ។

នាយក នាយិកា នាយករង នាយិការងគ្រឹះស្ថានសិក្សា បឋមសិក្សា និងមធ្យមសិក្សាសរុប ១៣ ៣០១ នាក់ ស្រី ២ ៣៩៣ នាក់ ត្រូវជា ១៧,៩៩ ភាគរយ។

គ្រូបង្រៀនទូទាំងប្រទេស មាន ១០០ ០៤៨នាក់ ស្រី ៥៣ ៥៦៨នាក់ ត្រូវជា ៥៣,៥៤ ភាគរយ ក្នុងគ្រូបង្រៀននៅទីប្រជុំជន មាន ២៩ ៩២៧ នាក់ ស្រី ១៦៤ ៣៩នាក់ ត្រូវជា ៥៤,៩៣ ភាគរយ និងគ្រូបង្រៀននៅជនបទ មាន ៥៧ ៧៦០នាក់ ស្រី ៣០ ៦២៤នាក់ ត្រូវជា ៥៣,០២ ភាគរយ។

ប្រកាសដាក់បុគ្គលិកអប់រំឱ្យចូលនិវត្តន៍ ឆ្នាំ២០២៤ ចំនួន ៦៧០នាក់ ស្រី ២២៧នាក់ និងឆ្នាំ២០២៥ ចំនួន ៨៨១នាក់ ស្រី ៣៦៦នាក់។

តាំងស៊ប់ឆ្នាំ២០២៣ ក្របខ័ណ្ឌជូនគ្រូបង្រៀនចេញថ្មី ១ ១៩១នាក់ ស្រី ៦២២នាក់ ក្នុងនោះ គ្រូបង្រៀនឧត្តមកម្មសិក្សា ៧៨៣នាក់ ស្រី ៣៨៨នាក់ គ្រូបង្រៀនមូលដ្ឋានកម្មសិក្សា ១៨៤ នាក់ ស្រី ១១០នាក់ គ្រូបង្រៀនបឋមកម្មសិក្សា ២២៤នាក់ និងតាំងស៊ប់អតីតបុគ្គលិកឆ្នាំ២០២៣ចំនួន ៥៣នាក់ ស្រី ២០នាក់ ក្នុងនោះ គ្រូបង្រៀនឧត្តមកម្មសិក្សា ៣៩នាក់ ស្រី ១៧នាក់ និងគ្រូបង្រៀនមូលដ្ឋានកម្មសិក្សា ១៤នាក់ ស្រី ៣នាក់។

ដំឡើងឋានន្តរស័ក្តិ និងថ្នាក់តាមវេនឆ្នាំ២០២៤ ជូនបុគ្គលិកអប់រំ ៨៨ ១៧៩នាក់ ស្រី ៤០ ០១៦ នាក់ ក្នុងនោះព្រះរាជក្រឹត្យ ៥ ៥៨៩នាក់ ស្រី ១ ៣៥១នាក់ អនុក្រឹត្យ ៥ ៨៣៥នាក់ ស្រី ១ ៨១៤នាក់ និងប្រកាស ៧៦ ៧៥៥នាក់ ស្រី ៣៦ ៨៥១នាក់ និងដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រសម្រាប់ឆ្នាំ២០២៤ ចំនួន ១ ៣១៣នាក់ ស្រី ៥៥១នាក់។

ប្រកាសតែងតាំងមន្ត្រីគ្រប់គ្រង ១៧០នាក់ ស្រី ៣២នាក់ និងសម្រួលភារកិច្ចមន្ត្រី ១១នាក់ ស្រី ១នាក់។

ផ្តល់ពានរង្វាន់ **សម្តេចតេជោសែន** ប្រចាំឆ្នាំសិក្សា២០២៣-២០២៤ ជូននាយកសាលាល្អ ១០នាក់ ស្រី ២នាក់ គ្រូបង្រៀនល្អ ១០នាក់ ស្រី ៣នាក់ គ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១០នាក់ ស្រី ៧នាក់ គ្រូបង្រៀនល្អគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១០នាក់ ស្រី ៨នាក់ និងសាលាស្អាតចំនួន ១០សាលា (បឋមសិក្សា ២ និងវិទ្យាល័យ ៨)។ ផ្តល់ប័ណ្ណសរសើរលើកទឹកចិត្តជូន នាយកសាលាចំនួន ១០នាក់ ស្រី ១នាក់ គ្រូបង្រៀនចំនួន ១០ នាក់ ស្រី ១នាក់ គ្រូបង្រៀនភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១០នាក់ ស្រី ៨នាក់ គ្រូបង្រៀនគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១០នាក់ ស្រី ៦នាក់ និងសាលារៀនស្អាតចំនួន ១០សាលា (បឋមសិក្សា ២ អនុវិទ្យាល័យ ២ និងវិទ្យាល័យ ៦)។

## ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាព

- ក្រសួងបាននិងកំពុងអនុវត្តការបញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ នៅសាលាគរុកោសល្យទាំងអស់ចំនួន ១៥ម៉ោង
- ក្រសួងបានធ្វើកំណែទម្រង់គ្រឹះស្ថានអប់រំគ្រូបង្រៀន ដោយបានបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ១២+៤ បរិញ្ញាបត្រ+១ សម្រាប់គ្រូបឋមសិក្សា និងគ្រូកម្រិតអប់រំមូលដ្ឋាន នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង និងបរិញ្ញាបត្រ+២ សម្រាប់គ្រូកម្រិតឧត្តមនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន និងគុណភាពនៃការបង្រៀននៅតាមគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាសាធារណៈ
- ក្រសួងបន្តសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីគាំទ្រក្នុងការលើកកម្ពស់គុណភាពនៃការបង្រៀនលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ពិសោធន៍ កុំព្យូទ័រ បញ្ញាសប្បនិម្មិត ភាសាបរទេស និងបណ្ណាល័យ នៅតាមសាលារៀនជំនាន់ថ្មី សាលាធនធាន សាលាមធ្យមសិក្សា
- ក្រសួងបានដាក់ចេញវិធានការកំណែទម្រង់ការគ្រប់គ្រងបុគ្គលិក ឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ កន្លងមកនេះ ការអនុវត្តកម្មវិធីជាតិ និងវិធានការកំណែទម្រង់បានធ្វើឱ្យបុគ្គលិកអប់រំនៅទូទាំងប្រទេសមានការពេញចិត្ត និងបន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅគ្រប់ភូមិសិក្សា ក្នុងគោលដៅឆ្លើយតបនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ត្រឹមឆ្នាំ២០២៥ ប្រាក់បៀវត្សសម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិអប្បរមាទទួលបាន ១ ៧២៧ ៣៥០រៀល គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិអប្បរមាទទួលបាន ១ ៦៧៩ ០០០រៀល និងគ្រូបង្រៀនកម្រិតបឋមសិក្សា និងមត្តេយ្យសិក្សាទទួលបាន ១ ៥៩៦ ៩៥០រៀល។ ប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន ត្រូវបានដំឡើងពី ៦០០ ០០០រៀល ទៅ ៨០០ ០០០រៀល។ ការឧបត្ថម្ភប្រាក់ដល់គរុសិស្ស គរុនិស្សិតដែលកំពុងសិក្សាទទួលបាន៧០% នៃប្រាក់បៀវត្សសរុប ក្នុងនោះមានគរុនិស្សិត កម្រិត "ក" ទទួលថវិកាបាន ១ ១៧០ ០០០រៀល កម្រិត "ខ" ទទួលបានថវិកា ១ ១០០ ០០០រៀល កម្រិត "គ" ទទួលបានថវិកា ៩៨០ ០០០រៀល នៅឆ្នាំ២០២៤
- ក្រសួងបានរៀបចំសៀវភៅណែនាំប្រតិបត្តិការងារគ្រប់គ្រងបុគ្គលិកអប់រំនៅតាមសាលារៀនដើម្បីពង្រឹងការគ្រប់គ្រងបុគ្គលិកនៅកម្រិតសាលារៀនឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងឆ្លើយតបតាមតម្រូវការជាក់ស្តែង ដែលបានដាក់ឱ្យអនុវត្តការងារគ្រប់គ្រងបុគ្គលិកតាមសាលារៀន នៅឆ្នាំ២០២២
- ក្រសួងបានបន្តអនុវត្តកម្មវិធីសិក្សាបំណិនជីវិតសម្រាប់កម្រិតបឋមសិក្សា (ថ្នាក់ទី៥-៦) សាលាមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៨) សាលាមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី ១០-១១) និងសម្រាប់យុវជនក្រៅសាលា

- ក្រសួងបានបន្តអនុវត្តកម្មវិធីអប់រំ សុខភាពសិក្សារួមមានៈ ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទកម្រិតមូលដ្ឋាន មេរោគអេដស៍/ជំងឺអេដស៍ អនាម័យ និងទស្សនៈយេនឌ័រ (ពីថ្នាក់ទី៥-៦) តួនាទីយេនឌ័រ លក្ខណៈភេទ ការសម្ដែងចេញ លក្ខណៈភេទ និងយេនឌ័រ (ពីថ្នាក់ទី៧-៨) និងសិទ្ធិមនុស្ស សមភាពយេនឌ័រ តួនាទីយេនឌ័រ ការបៀតបៀនផ្លូវភេទ និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (ពីថ្នាក់ទី១០-១១)។

## ២.៣ បញ្ហាប្រឈម

- កង្វះហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាព និងគ្រឹះស្ថានសិក្សាមួយចំនួន ដូចជាៈ បង្គន់អនាម័យស្តង់ដា ប្រព័ន្ធទឹកស្អាត អគ្គិសនី និងអ៊ីនធឺណិត
- ការទទួលបន្ទុករបស់ស្ត្រីក្នុងគ្រួសារ និងផ្នត់គំនិតក្នុងសង្គមពាក់ព័ន្ធនឹងរបៀបរៀបអាពាហ៍ពិពាហ៍នៅតែចោទជាបញ្ហាទៅលើការធានាសមភាព និងសមធម៌យេនឌ័រក្នុងវិស័យអប់រំ
- ការបណ្តុះបណ្តាល បុគ្គលិកអប់រំលើការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ ក្រោមជាតិ និងសាលារៀនមិនទាន់បានទូលំទូលាយ
- ខេត្តមួយចំនួនមិនទាន់មានលទ្ធភាពបង្កើតគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើនការចូលរៀន ប្រកបដោយសមធម៌ និងទប់ស្កាត់ការបោះបង់ការសិក្សារបស់និស្សិតស្រី
- ចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ គ្រប់គ្រងក្នុងវិស័យអប់រំនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀនមានចំនួនតិចនៅឡើយ
- ការកសាងអន្តេវាសិកដ្ឋានសម្រាប់ការស្នាក់នៅរបស់សិស្សស្រី និស្សិតនារីមិនទាន់ឆ្លើយតបទៅនឹងតម្រូវការ នៅតាមគ្រឹះស្ថានសិក្សា
- សិស្ស និស្សិតនារីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅមានចំនួនតិចនៅឡើយ។

## ៣. ចក្ខុវិស័យ

លុបបំបាត់គម្លាតយេនឌ័រ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានឱកាសពេញលេញ និងសេវាអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។

## ៤. បេសកកម្ម

ផ្តល់លទ្ធភាពឱ្យកុមារ និងមនុស្សពេញវ័យគ្រប់រូបទទួលបានអត្ថប្រយោជន៍ដូចគ្នា ទាំងការចុះឈ្មោះចូលរៀន ការបន្តការសិក្សា និងលទ្ធផលសិក្សានៅគ្រប់កម្រិតតាមរយៈ៖

- លើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីក្នុងវិស័យអប់រំ
- បង្កើនតួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចក្នុងវិស័យអប់រំ
- បង្កើនការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធ ដើម្បីផ្តល់កិច្ចអន្តរាគមន៍ឆ្លើយតបនឹងតម្រូវការ និងការកែលម្អគុណភាពអប់រំនៅគ្រប់ភូមិសិក្សាទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ
- លើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ដើម្បីស្វែងរកលទ្ធភាព និងវិធានការឆ្លើយតប។

## ៥. គោលបំណង

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ មានគោលបំណង "ធានាឱ្យកុមារ និងមនុស្សពេញវ័យ ទទួលបានសេវាអប់រំប្រកបដោយសមភាព សមធម៌ បរិយាបន្ន និងសម្រេចបានលទ្ធផលសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព"។ ដើម្បីសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវគោលដៅចំនួនបីដូចខាងក្រោម ៖

- ធានាសម្រេចឱ្យបានសមភាពយេនឌ័រក្នុងការចូលរៀន និងរៀនប្រកបដោយគុណភាព សមភាព សមធម៌ និងបរិយាបន្ននៅគ្រប់ភូមិសិក្សា ទាំងក្នុង និងក្រៅប្រព័ន្ធ
- ធានាបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជាស្ត្រីក្នុងការផ្តល់សេវាអប់រំប្រកបដោយបរិយាបន្ន
- ធានាឱ្យបរិស្ថានអប់រំ និងការបណ្តុះផ្នត់គំនិត និងឥរិយាបថប្រកបដោយវិជ្ជមាន ឆ្លើយតបនឹងយេនឌ័រ។

## ៦. ក្របខណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២៥-២០២៩ បានដាក់ចេញយុទ្ធសាស្ត្រ យុទ្ធសាស្ត្ររង និងសកម្មភាពចម្បងដូចខាងក្រោម ៖

### យុទ្ធសាស្ត្រទី១៖ លើកកម្ពស់ការសិក្សាស្រាវជ្រាវ វិភាគ ផ្សព្វផ្សាយលិខិតបទដ្ឋាន និងគោលនយោបាយ បង្កើនការយល់ដឹងអំពីយេនឌ័រ

**យុទ្ធសាស្ត្ររង១.១៖ បង្កើនការសិក្សាស្រាវជ្រាវ វិភាគ និងបោះពុម្ពឯកសារ អំពីស្ថានភាពយេនឌ័រក្នុងវិស័យអប់រំ**

- ពិនិត្យឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាល និងឯកសារពាក់ព័ន្ធនឹងយេនឌ័រលើការទទួលខុសត្រូវនៅក្នុងវិស័យអប់រំ

- ប្រមូល និងគ្រប់គ្រងទិន្នន័យព័ត៌មានស្តីពី តម្រូវការអប់រំ ស្ថានភាពកុមារ យុវជនក្នុងនិងក្រៅសាលា ពិសេសកុមារងាយរងគ្រោះ មានពិការភាព ជនជាតិដើមភាគតិច ដែលបាត់បង់ឱកាស
- វិភាគការចូលរៀន ការជ្រើសរើសបណ្តុំមុខវិជ្ជា លទ្ធផលសិក្សា គុណភាពអប់រំ និងតម្រូវការហេដ្ឋា-រចនាសម្ព័ន្ធអប់រំប្រែកបដោយបរិយាបន្ន ផ្តោតលើអគារសិក្សា ជម្រាល បន្ទប់រៀន គ្រូបង្រៀន សម្ភារបង្រៀននិងរៀន បន្ទប់ទឹក កន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យ សម្រាប់ប្រុស និងស្រី
- បោះពុម្ពចែកផ្សាយ និងផ្សព្វផ្សាយឯកសារស្រាវជ្រាវស្តីពី ការវិភាគស្ថានភាពយេនឌ័រក្នុងវិស័យអប់រំ។

**យុទ្ធសាស្ត្រទី១.២ ៖ បង្កើនការផ្សព្វផ្សាយឯកសារពាក់ព័ន្ធនិងយេនឌ័រ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សា**

- ផ្សព្វផ្សាយគោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្តនានា ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ និងរបាយការណ៍វឌ្ឍនភាពដែលពាក់ព័ន្ធទៅនឹងការលើកកម្ពស់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី
- ផ្សព្វផ្សាយព័ត៌មានអំពីការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើស្ត្រីនិងកុមារ ជាពិសេស ការឆបោកតាមប្រព័ន្ធអនឡាញ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ
- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាគម្លាតយេនឌ័រក្នុងវិស័យអប់រំ តាមរយៈសិក្ខាសាលា យុវជន និងក្រុមប្រឹក្សាកុមារកម្ពុជា ក្នុងវេទិកាផ្សេងៗ គេហទំព័រក្រសួងអប់រំ យុវជន និងកីឡា និងបណ្តាញទំនាក់ទំនងសង្គម
- ជំរុញក្រុមការងារយេនឌ័រនៅតាមអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សា លើការរៀបចំផែនការសកម្មភាពពាក់ព័ន្ធនឹងយេនឌ័រ និងក្របខណ្ឌការងារជាក់លាក់ ដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ។

**យុទ្ធសាស្ត្រទី១.៣ ៖ លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ**

- បណ្តុះបណ្តាលមន្ត្រីអប់រំទទួលបន្ទុកការងារយេនឌ័រ អំពីការវិភាគស្ថានភាពយេនឌ័រក្នុងវិស័យអប់រំ និងបញ្ហាគម្លាតការចូលរៀន និងលទ្ធផលសិក្សារវាងសិស្សស្រី និងសិស្សប្រុសនៅគ្រប់ភូមិសិក្សា
- បញ្ចូលខ្លឹមសារពាក់ព័ន្ធនឹងយេនឌ័រទៅក្នុងគោលនយោបាយអប់រំ និងលិខិតបទដ្ឋានគតិយុត្ត
- បញ្ចូលសកម្មភាពពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងគម្រោងនានាក្នុងវិស័យអប់រំ
- ធ្វើបច្ចុប្បន្នភាពក្រុមការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បញ្ជ្រាបឥរិយាបថវិជ្ជមាន និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សា។

## យុទ្ធសាស្ត្រទី២៖ បង្កើនភាពទាក់ទាញដល់បុគ្គលដែលមានសមត្ថភាព

### យុទ្ធសាស្ត្ររង២.១ ៖ បង្កើនការគាំទ្រដល់ការអនុវត្តសកម្មភាពយេនឌ័រក្នុងវិស័យអប់រំ

- បង្កើតវេទិកាដើម្បីស្វែងរកការគាំទ្រស្ត្រីឱ្យមានមុខតំណែងក្នុងការធ្វើសេចក្តីសម្រេច និងរក្សាទុកមុខដំណែងដែលជាអាទិភាពសម្រាប់ស្ត្រី
- រៀបចំឯកសារ ឬសៀវភៅណែនាំភាពជាអ្នកដឹកនាំសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- លើកកម្ពស់សមភាពយេនឌ័រក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចក្នុងវិស័យអប់រំ
- ពង្រឹង និងពង្រីកសកម្មភាពប្រឹក្សាសាលារៀន ក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ
- បង្កើតវេទិកា ចែករំលែកបទពិសោធន៍ល្អៗ របស់យុវជន និងកុមារ ដែលមានស្នាដៃឆ្នើមក្នុងការងារ និងការសិក្សា
- ធ្វើបច្ចុប្បន្នកម្មចំនួនស្ត្រីក្នុងមុខតំណែងនីមួយៗ។

### យុទ្ធសាស្ត្ររង២.២ ៖ បង្កើនការចូលរួម និងការគាំទ្រសកម្មភាពយេនឌ័រក្នុងវិស័យអប់រំ

- ផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់បុគ្គលិកអប់រំ និងអង្គភាពដែលមានស្នាដៃក្នុងការបំពេញការងារយេនឌ័រនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សា
- បង្កើនកិច្ចសហការជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រការតែងតាំងស្ត្រីក្នុងមុខតំណែងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច នៅតាមអង្គភាពរដ្ឋបាល និងគ្រឹះស្ថានសិក្សា
- លើកទឹកចិត្តស្ត្រី និងក្មេងស្រី ឱ្យមានភាពអង់អាចលើការធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមចែករំលែកបទពិសោធ
- បង្កើនការលើកទឹកចិត្តក្នុងការចូលរួមរបស់សិស្សស្រី សិស្សមានពិការភាព និងសិស្សជនជាតិដើមភាគតិចលើគ្រប់សកម្មភាព
- លើកទឹកចិត្តឱ្យមានការចូលរួមគ្រប់សកម្មភាពអប់រំកាយ និងកីឡា និងសកម្មភាពសង្គម ពិសេសសិស្សស្រីនៅគ្រប់គ្រឹះស្ថានសិក្សា
- ផ្តល់ការគាំទ្រ និងជំរុញការចូលរួមមតិយោបល់របស់ស្ត្រី ដែលជាសមាសភាពរបស់ក្រុមប្រឹក្សាវិន័យនៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានសិក្សា
- ផ្តល់ឱកាសដល់ស្ត្រី ក្នុងការងារសង្គមដោយមានការគាំទ្រពីសហគមន៍ អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ
- រៀបចំបរិស្ថានកន្លែងការងារឱ្យសមស្របសម្រាប់ស្ត្រី ដើម្បីបង្កើនភាពធន់ និងឆ្លើយតបការប្រែប្រួលអាកាសធាតុ
- ចូលរួមលើកកម្ពស់សុខុមាលភាពគ្រួសារ តាមរយៈការផ្តល់កម្មវិធីអប់រំមាតាបិតាស្តីពី ការចិញ្ចឹមបីបាច់កុមារតូច ការចិញ្ចឹមកូនតាមបែបវិជ្ជមាន និងបង្កើតកម្មវិធីអប់រំកុមារតូចនៅតាមរោងចក្រ សហគ្រាស និងនៅតំបន់សេដ្ឋកិច្ចពិសេស។

## យុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធឱ្យមានសមភាពយេនឌ័រ

### យុទ្ធសាស្ត្រវង៣.១៖ វិភាគតម្រូវការអភិវឌ្ឍសមត្ថភាពស្ត្រី និងមន្ត្រីពាក់ព័ន្ធ

- សិក្សា វិភាគស្ថានភាព និងកំណត់ក្រុមគោលដៅសម្រាប់ការអភិវឌ្ឍសមត្ថភាពយេនឌ័រក្នុងវិស័យអប់រំ
- រៀបចំផែនការសកម្មភាព ផែនការថវិកា និងខ្លឹមសារអភិវឌ្ឍសមត្ថភាពឱ្យឆ្លើយតបនឹងយេនឌ័រនៅគ្រប់កម្រិត។

### យុទ្ធសាស្ត្រវង៣.២៖ បង្កើនសកម្មភាពអភិវឌ្ឍសមត្ថភាព

- បំប៉នសមត្ថភាពគណៈគ្រប់គ្រង និងក្រុមការងារយេនឌ័រ គ្រូឧទ្ទេស និងមន្ត្រីបង្គោលយេនឌ័រអំពីយេនឌ័រនៅតាមអង្គភាព សហព័ន្ធកីឡាជាតិ និងស្ថាប័នពាក់ព័ន្ធ ដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ
- តម្រង់ទិសការអនុវត្ត និងបំប៉នសមត្ថភាពអំពី សមភាពយេនឌ័រក្នុងការអប់រំសម្រាប់ក្រុមប្រឹក្សាសាលារៀន ក្រុមប្រឹក្សាយុវជននិងកុមារ យុវជនកាកបាទក្រហម និងយុវជនកាយរិទ្ធិ តាមគ្រឹះស្ថានសិក្សា សហព័ន្ធកីឡាជាតិ និងសហគមន៍
- បំប៉នមន្ត្រីគ្រប់គ្រង និងមន្ត្រីជំនាញអំពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ការរៀបចំផែនការ និងការរៀបចំផែនការថវិកាឆ្លើយតបនឹងយេនឌ័រនៅគ្រប់កម្រិត
- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំជាពិសេសស្ត្រីលើជំនាញសតវត្សទី២១
- បញ្ជ្រាបចំណេះដឹងអំពីការងារយេនឌ័រក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ ការអប់រំបំណិនជីវិតមូលដ្ឋាន សុខភាពបន្តពូជ សុខភាពផ្លូវភេទ និងកម្មវិធីបណ្តុះបណ្តាលនានា
- បំប៉នសមត្ថភាពគ្រូឧទ្ទេស និងជនបង្គោលស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងការអប់រំគ្រូបង្រៀន
- អភិវឌ្ឍសមត្ថភាពស្តីពី សហគ្រិនភាពភាពជាអ្នកដឹកនាំ និងការគាំទ្រដល់ស្ត្រីក្នុងការដឹកនាំ និងគ្រប់គ្រងលើអាជីវកម្ម ប្រកបដោយនវានុវត្តន៍ និងភាពឆ្នៃប្រឌិតខ្ពស់
- ចែករំលែកឧត្តមានុវត្តន៍ និងធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធតាមតំបន់ ក្នុងនិងក្រៅប្រទេសពាក់ព័ន្ធយេនឌ័រ។

### យុទ្ធសាស្ត្រវង៣.៣ ៖ ពិនិត្យតាមដាន វាយតម្លៃ និងកំណត់ទិសដៅសកម្មភាពបន្ត

- ពិនិត្យតាមដានការអនុវត្តសកម្មភាពជាប្រចាំនៅតាមអង្គភាព និងស្ថាប័នពាក់ព័ន្ធ
- រៀបចំប្រជុំតាមប្រតិទិនការងារជាមួយក្រុមគោលដៅ និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅនៃការអនុវត្តនៃការងារយេនឌ័រក្នុងវិស័យអប់រំ
- រៀបចំរបាយការណ៍វឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅនៃការងារយេនឌ័រក្នុងវិស័យអប់រំ តាមឆមាស និងប្រចាំឆ្នាំ។

## យុទ្ធសាស្ត្រទី៤ ៖ បញ្ជ្រាបយេនឌ័រក្នុងដំណើរការបង្រៀន និងរៀន

### យុទ្ធសាស្ត្រវង៤.១ ៖ បញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីសិក្សា និងកម្មវិធីអប់រំគ្រូបង្រៀន

